**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ ៤៣.៤២.០២៥ សជ ៣៧

# សេចក្តីជូនដំណឹង
## ស្តីពីការដាក់ឱ្យអនុវត្តយន្តការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ នៅតាមបណ្តាស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ជូនប្រជាពលរដ្ឋខ្មែរចំណាកស្រុក

ដើម្បីពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាឱ្យកាន់តែប្រសើរជូនប្រជាពលរដ្ឋ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា **ក្រសួងមហាផ្ទៃ** មានកិត្តិយសសូមជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋខ្មែរទូទៅឱ្យបានជ្រាបថា **ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៦** តទៅ **អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ** នឹងដាក់ឱ្យអនុវត្តយន្តការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ នៅតាមបណ្តាស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ជូនប្រជាពលរដ្ឋខ្មែរចំណាកស្រុក ដែលកំពុងប្រកបការងារ ឬមុខរបរ ឬបន្តការសិក្សា នៅក្រៅរាជធានី ខេត្ត នៃលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួន។ មានន័យថា ប្រជាពលរដ្ឋខ្មែរចំណាកស្រុកទាំងពីរភេទ អាចទៅស្នើសុំធ្វើអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬបន្តសុពលភាពអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ នៅតាមបណ្តាស្នងការដ្ឋាននគរបាលរាជធានី ខេត្តណាមួយក៏បាន ដោយពុំចាំបាច់ត្រឡប់ទៅលំនៅឋានដើមឡើយ។ ឧទាហរណ៍៖ ប្រជាពលរដ្ឋមានលំនៅឋានអចិន្ត្រៃយ៍នៅខេត្តរតនគិរី ហើយបានទៅប្រកបការងារនៅខេត្តព្រៃវែង អាចស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនៅស្នងការដ្ឋាននគរបាលខេត្តព្រៃវែងបាន។

លក្ខខណ្ឌ និងឯកសារភ្ជាប់ផ្សេងៗ សម្រាប់ពលរដ្ឋខ្មែរទូទៅ (មិនមែនចំណាកស្រុក) និងពលរដ្ឋខ្មែរចំណាកស្រុក មានដូចខាងក្រោម៖

I. **សម្រាប់ពលរដ្ឋទូទៅ (មិនមែនចំណាកស្រុក) អាចស្នើសុំនៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ ឬអធិការដ្ឋាននគរបាលក្រុង-ស្រុក-ខណ្ឌ ឬស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួន**

ក. **ចំពោះប្រជាពលរដ្ឋខ្មែរដែលមានអាយុ ១៥ឆ្នាំឡើង ហើយមិនទាន់មានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរប្រើប្រាស់** ត្រូវភ្ជាប់មកជាមួយនូវ៖

- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត
- ឯកសារសម្គាល់ការស្នាក់នៅ (សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅ)។

ខ. **ចំពោះប្រជាពលរដ្ឋមានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដែលអស់សុពលភាព ឬសុពលភាពនៅតិចជាង ១៨០ថ្ងៃ** ត្រូវភ្ជាប់មកជាមួយនូវ៖

- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលអស់សុពលភាព ឬសុពលភាពនៅតិចជាង **១៨០ថ្ងៃ**
- ចំពោះករណីផ្លាស់ប្តូរអាសយដ្ឋានថ្មី (អចិន្ត្រៃយ៍) សូមភ្ជាប់មកជាមួយនូវឯកសារសម្គាល់ការស្នាក់នៅ (សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅ នៃលំនៅឋានថ្មី)។

**គ. ចំពោះការស្នើសុំអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដែលបាត់បង់ ឬខូចខាត៖**

- ករណីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលបាត់បង់ ត្រូវភ្ជាប់មកជាមួយនូវពាក្យបណ្ដឹងអំពីការបាត់បង់
- ករណីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលខូចខាត ត្រូវភ្ជាប់មកជាមួយនូវអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលខូចខាតនោះមកជាមួយ។

II. **សម្រាប់ពលរដ្ឋខ្មែរចំណាកស្រុក អាចស្នើសុំនៅស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ឬនៅទីស្នាក់ការផ្ដល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរក្នុងផ្សារទំនើបអ៊ីអន២ ខណ្ឌសែនសុខ ឬក្នុងផ្សារទំនើបអ៊ីអន៣ ខណ្ឌមានជ័យ ឬនៅនាយកដ្ឋានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ**

**ក. ចំពោះប្រជាពលរដ្ឋខ្មែរចំណាកស្រុក ដែលមានអាយុ ១៥ឆ្នាំឡើង ហើយមិនទាន់មានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរប្រើប្រាស់** ត្រូវភ្ជាប់មកជាមួយនូវ៖

- សេចក្ដីចម្លងសំបុត្រកំណើត ឬសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត
- ឯកសារសម្គាល់ការស្នាក់នៅ (សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅ)។

**ខ. ចំពោះប្រជាពលរដ្ឋខ្មែរចំណាកស្រុក ដែលមានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដែលអស់សុពលភាព ឬសុពលភាពនៅតិចជាង ១៨០ថ្ងៃ** ត្រូវភ្ជាប់មកជាមួយនូវអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលអស់សុពលភាព ឬសុពលភាពនៅតិចជាង ១៨០ថ្ងៃ។

**គ. ចំពោះការស្នើសុំអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដែលបាត់បង់ ឬខូចខាត៖**

- ករណីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលបាត់បង់ ត្រូវភ្ជាប់មកជាមួយនូវពាក្យបណ្ដឹងអំពីការបាត់បង់
- ករណីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលខូចខាត ត្រូវភ្ជាប់មកជាមួយនូវអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលខូចខាតនោះមកជាមួយ។

មន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវពិនិត្យ ផ្ទៀងផ្ទាត់សលាកបត្រស្នើសុំ ជាមួយឯកសារពាក់ព័ន្ធផ្សេងៗឱ្យបានត្រឹមត្រូវ និងធ្វើការសម្ភាស ដើម្បីកំណត់អត្តសញ្ញាណជាពលរដ្ឋខ្មែរឱ្យបានច្បាស់លាស់ស្របតាម**ប្រការ១៧** និង**ប្រការ១៩** នៃ**ប្រកាសលេខ៤២២១ ប្រក** ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៥ របស់**ក្រសួងមហាផ្ទៃ**។ ទន្ទឹមនេះ មន្ត្រីចុះបញ្ជី និងប្រជាពលរដ្ឋត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ នូវរាល់ព័ត៌មានដែលបានចុះបញ្ជី និងការផ្ដល់ព័ត៌មានក្លែងក្លាយ ឬឯកសារក្លែងក្លាយដោយចេតនាដូចបានប្បញ្ញត្តិក្នុង**មាត្រា១៦៩** និង**មាត្រា១៧១** នៃច្បាប់ស្ដីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។

ឆ្លៀតក្នុងឱកាសនេះ **អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ** សូមអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរទាំងអស់ ដែលកាន់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរអស់សុពលភាព ឬសុពលភាពនៅតិចជាង **១៨០ថ្ងៃ** សូមមេត្តារួសរាន់ទៅបំពេញបែបបទស្នើសុំប្ដូរអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរថ្មី ចៀសវាងការប្រើប្រាស់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលអស់សុពលភាព (មិនអាចប្រើប្រាស់បាន)។

**❖ សម្រាប់ព័ត៌មានផ្សេងៗ សូមទាក់ទងទៅកាន់លេខ៖ ១២៧១ ឬ ០១៧ ៨៩៨ ៩១៥**

ថ្ងៃចន្ទ ១៤កើត ខែបុស្ស ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមករា ឆ្នាំ២០២៦